## ភាគទី ៧

# ការនិរទេសបាណ្ឌពក្សត្រយ៍

បាណ្ឌពក្សត្រិយ៍ ជេដ្ឋកនិដ្ឋាទាំង ៥ អង្គ ព្រមដោយទ្រៅបទី ទេវីដែលត្រូវគេនិរទេសចាកភារា ក៏ស្តេចនាំគ្នាចរលីលា ចេញពីក្រុងសន្សឹម ៗ ទៅ បែរព្រះភក្រ្តឆ្ពោះទៅអរញ្ញប្រទេសដែនដងព្រៃ, ព្រះភក្រ្តស្លក់ស្លាំង, ព្រះឱស្ឋស្ងួតក្រៀម, ព្រះនេត្រអាប់ឥតរស្មី ។ អ្នកបានជួបប្រទះឃើញស្តេច តាមផ្លូវតាមព្រៃក៏ដកដង្ហើមធំរាល់ ៗ គ្នា ។ ស្តេចនាំគ្នាត្រាច់យាត្រាតគ្រុកទៅលែងចរចា ហាក់ដូចជាថា បើបើកព្រះឱស្ឋត្រាស់ចេញទៅ ក្រែងហួសកម្លាំងហាឫទ័យ ដែលនឹងទទួលទ្រាំទ្របាន ។ នៅវេលាមួយក្សត្រិយ៍ ១ អង្គក្នុងពួកនោះ លាន់វាចាចេញមកថា «តាំងវេលានេះរហូតទៅទល់នឹងពេលដែលខ្ញុំបានឃើញក្បាល ទុរយោធន៍ ដោតនៅចុងព្រះសែងធ្នូនេះ ខ្ញុំលែងបានសេចក្តីស្ងប់ នឹងសុខចិត្តជាដាច់ខាត» អរជុនថ្លែង ។

សហទេពក៏គិតឃើញប្រហែលគ្នាដែរ ទើបឆ្លើយឆ្លងតាំងសច្ចាប្រណិធានរបស់ខ្លួនថា«ខ្ញុំនឹងមិនតម្លោះធ្នូនេះ រហូតដល់ព្រួញធ្នូនេះបានស៊ីសាច់ផឹកឈាមអាចោរកំណាចទាំងនោះជាមុនឡើយ» ។

អង្គទី ៣ អស្សុជលដោកកក្ត្រា មានបន្ទូលឆ្លើយឆ្លងឡើងថា «កាលវាមើលងាយ ទ្រៅបទី ខ្ញុំទប់ទឹកភ្នែកមិនបានសោះ ប៉ុន្តែឥឡូវ



នេះខ្ញុំតាំងសច្ចាប្រណិធានទុកក្នុងចិត្តថា ខ្ញុំនឹងមិនសឹកក្របីនេះចូលក្នុងស្រោមឡើយ លុះត្រាតែខ្ញុំបានយកឈាមអាពួកអប្បល័ក្ខណ៍ទាំងនោះ មកលាបមុខក្របីនេះជាមុនសិន ទើបបានខ្ញុំសឹកចូលក្នុងស្រោម» ។

អង្គទី ៤ នឹកក្តៅក្រហាយក្នុងព្រះទ័យណាស់ ចង់និយាយស្បថស្បែទុកជាច្រើនប្រការ ទើបលើកព្រះហស្តដ៏មាំឡើងបន្លឺវាចាថា «ដៃនេះនឹងមិនឈប់សម្រាកឲ្យសប្បាយទេ លុះត្រាតែខ្ញុំបានរំលាងអាពួកកំណាចចិត្តទមិឡ ឲ្យរលីងអស់ទៅអំពីផែនធរណី ទើបដៃសម្រាកបាន» ។

ចំណែកឯយុធិស្ឋិរមិនត្រាស់ថាអ្វីឡើយ ចេះតែដាក់ព្រះភក្រ្តស្រងូតនៅពេលដែលអនុភាតាសច្ចាប្រណិធានផ្សេង ៗ គ្នា មើលទៅព្រះអាការៈស្រងូតស្រងាត់ពេញទៅដោយសេចក្តីជញ្ជឹង ដូចជាមិនជ្រាបថាមានហេតុភេទអ្វីខាងក្រៅទេ ជ្រាបចំពោះតែហេតុក្នុងព្រះទ័យប៉ុណ្ណោះ ស្តេចធ្វើដំណើរទៅតាមមាគ៌ា ព្រះសិរឱនក្រងុលចេះតែរុលត្បុលទៅមុខ ឥតក្រឡេកទតនាយអាយសោះ ព្រះភក្រ្តជោកទៅដោយអស្សុជល យូរ ៗ ដកដង្ហើមធំ ។

ឯទ្រៅបទីសោត មើលទៅព្រះភក្រ្តគួរឲ្យអាសូរជាងស្តេចប្រុស ៗ អស់នោះពេកណាស់ នាងទ្រង់សំពត់អំបោះ មិនទ្រង់សំពត់ព្រែដូចស្តេចស្រ្តីក្នុងព្រះនគរទេ ព្រះកេសារបស់នាងវែង សំយាក

ធ្លាក់គ្របលើស្មា ព្រះនេត្រគយគន់មើលតែទៅដី ឥតងើបងើយងាកមើលទៅទីដទៃឡើយ ហាក់ដូចជាសេចក្តីអាម៉ាស់មុខ ដែលនាងបានទទួលនោះ មកគ្របសង្កត់ព្រះទ័យ មិនអាចឲ្យទតទៅទីឯទៀតបាន បើចេះតែខំទតទៅមុខជានឹងទ្វេចំនួនទុក្ខ កាន់តែធ្ងន់ឡើង ៗ ។ នាងយាងហាលកំដៅថ្ងៃរាល់ទិវា ឥតវេលាណាដែលហៅថាស្រួលសោះ ចេះតែត្រូវកំដៅសូរ្យរង្សី គ្មានអ្វីបិទបាំងព្រះសិរឲ្យស្រន់អន់ក្តៅក្នុងអង្គសោះ ភក្ត្រផូរផង់របស់នាងត្រូវខ្យល់បក់បោកមកតាមផ្លូវក៏ក្រៀមក្រោះអស់រាសី លុះចូលវេលាសន្ធយារាត្រីកាល ទឹកសន្សើមក៏ធ្លាក់ បំព្រំបីដូចជាស្រពស្រោចភក្ត្រានាងហូរហៀររហាម លាយគ្នានឹងអស្សុធារា នាងខំយាត្រាតាមព្រះភស្តា មុខគួរឲ្យវេទនាមា-ល្បាយ ។

ការធ្វើដំណើរតាមផ្លូវនៅគ្រានោះ ពេលវេលាក៏កន្លងរំលងទៅកាន់តែច្រើនទិវារាត្រីហើយក្នុងទីបំផុតបានទៅដល់ព្រៃធំមួយឈ្មោះថា «កនកវន» ក្នុងព្រៃនោះងងឹតខ្លាំងណាស់ ទាល់តែទ្រង់ស្មានថាយប់សន្ធយានឹងមកដល់ឆាប់ ៗ ខុសពីប្រក្រតី ។ ឯដើមព្រឹក្សាក្នុងព្រៃនោះ ដុះជិតប្រកិតគ្នា កម្រព្រានព្រៃណានឹងច្រៀតជើងចូលទៅដល់ ។ អ្នកណាមួយឈានចូលទៅដល់ហើយ ដែលមិនត្រូវបន្លាមុតថ្ពក់ ឬប៉ះទង្គិច នឹងដើមឈើនោះគ្មានឡើយ ។ ការដែលលំបាកជាងនេះទៀត គឺថា ផ្លូវក្នុងព្រៃនោះពេញទៅដោយដុំថ្មធំតូចរដិបរដុប



កំទេចកំទីជល់ជំពប់ប៉ះព្រះបាទក្សត្រិយ៍ជេដ្ឋកនិដ្ឋាទាំងនោះ ជាដរាបទៅ, ជួនកាលក៏ជ្រុលជជ្រកបោកប៉ះទៅលើឈើ លើដុំថ្ម, ជួនកាលក៏ភ្លាត់ជើងរអិលធ្លាក់ទៅក្នុងជង្ហុក, ព្រះបាទាដែលទន់ត្រសួលរាល់ ៗ អង្គ ក៏ដាច់ដោចរលាត់រលាញជាំដាមខ្មៅចខ្មី ឥតទីស្រួលត្រង់ណាសោះឡើយ ទោះបីដល់ម្លឹងហើយក្តី ព្រៃធំត្រឈឹងត្រឈៃនោះបានជាទីជ្រកកោនអាស្រ័យម្លប់ម្យ៉ាងដែរមិនឲ្យត្រូវកំដៅព្រះអាទិត្យចែងចាំងខ្លាំងពេក ព្រោះបាំងបិទទៅដោយស្លឹកឈើ ប៉ុន្តែទាំងពីរយ៉ាងនោះ មិនដឹងជានឹងវិនិច្ឆ័យថាយ៉ាងណា លំបាកជាយ៉ាងណាទេ ព្រោះថាកំដៅព្រះសុរិយា ក៏ដុតពោលកាយឲ្យក្រៀមក្រោះ អាប់អស់រាសីដែរ ឯបន្លាសោតក៏មុតថ្ពក់រលាត់ ដាច់សាច់ចេញឈាមដែរ ។

ទីព្រៃស្រោងស្រឹងនោះ តែដល់ព្រលប់ព្រឹល ៗ ហើយ ក៏ងងឹតឈ្លប់ហាក់ដូចជាយប់ជ្រៅណាស់, រាត្រីសត្វក៏ចេញចាកទីលំនៅយាសយំទ្រហឹងអឹងកងតាមភេទភាសា គោចររកស៊ីក្នុងព្រៃធំស្មសាន ។ បាណ្ឌពក្សត្រិយ៍ ដែលត្រូវគេនិរទេសពីនិវេសន៍រាំងជ័យ ត្រូវត្រាច់រុកព្រៃមកដល់ត្រង់ទីកន្លែងនេះ ត្រូវជួបប្រទះនឹងភ័យក្នុងព្រៃមុខគួរឲ្យស្ញប់ស្ញែងនេះ មួយលើកទៀត ទ្រង់ផ្លាស់ប្តូរដាក់វេនគ្នា នៅចាំយាមប្រយ័ត្នការអន្តរាយ ឲ្យគ្រប់ ៗ អង្គ មានវេលាផ្ទំសម្រាកព្រះកាយបានតែមួយស្របក់ ៗ មួយអង្គតែប៉ុណ្ណោះ គ្រាន់នឹងឲ្យមានកម្លាំងចេញចរយាត្រាទៅពីព្រលឹម ផ្ទំតែបន្តិចបន្តួចដូចគេរត់គេដេញ

បានធ្វើរត្តិកាល ឲ្យកន្លងទៅរហូតដល់ភ្លឺដោយទំនងដូច្នេះ ។

លុះព្រឹកឡើង បាណ្ឌពក្សត្រិយ៍កំពុងតែនិទ្រានៅឡើយ ព្រោះក្នុងអរញ្ញប្រទេសនោះងងឹតសូន្យសុងគ្មានពន្លឺរស្មីលេចចូលទៅដល់ប្រាប់ពេលម៉ោងឡើយ មិនឃើញខែ មិនឃើញផ្កាយ ជាគ្រឿងសំគាល់ឲ្យដឹងរត្តិកាល ថាគោចរទៅហើយ បានប៉ុណ្ណោះប៉ុណ្ណោះយាម ឬម៉ោង សង្កេតដឹងបានតែដោយសារអាស្រ័យសម្លេងសត្វព្រៃស្រែកយំ ។ បាណ្ឌពក្សត្រិយ៍យាងផ្ទំនៅក្នុងព្រៃកនភវននោះ ទម្រាំតែលេចចេញវាលក៏ច្រើនទិវារាត្រី ប៉ុន្តែចំនួនប៉ុន្មានយប់ប៉ុន្មានថ្ងៃទ្រង់កំណត់ចាំមិនបានឡើយ ព្រោះនឿយព្រួយលំបាកព្រះកាយពលពេកណាស់ ដោយត្រាច់ចរវិលវល់ក្នុងព្រឹក្សព្រៃអស់កម្លាំងល្វិតល្វៃ ព្រះហឫទ័យក៏ស្មូលស្មោរទៅផងដែរ ទាល់តែភ្លេចនឹកគិតដល់រឿងថ្ងៃខែ ដែលកន្លងរំលងទៅហើយនោះ គ្រាន់តែចាំបានខ្លះដោយស្រពេចស្រពិល ។

ថ្ងៃមួយទ្រង់តើនឡើងហើយ ក៏នាំគ្នាយាងឆ្ពោះទៅទិសខាងជើងទៅដល់ជាយព្រៃមួយកន្លែងទាំងមិនដឹងខ្លួន បានឃើញពន្លឺភ្លឺមកពីខាងមុខក្នុងរយៈទីដ៏ឆ្ងាយ ប្រហែលគ្នានឹងពន្លឺដែលឆ្លុះចូលទៅក្នុងអណ្តូងដ៏ជ្រៅ ទ្រង់មានសេចក្តីសង្ឃឹមនឹងធូរស្រាលក្នុងទ្រូងតែរាល់ ៗ អង្គ ខំនាំគ្នារួតរះយាងសំដៅ ទៅត្រង់ពន្លឺនោះ មួយស្របក់ ក៏បានចេញផុតអំពីព្រៃធំ ទៅដល់កន្លែងដែលមើលឃើញពន្លឺពីចម្ងាយ



ទីនោះជាទីវាលខ្សាច់ធំ ឥតមានព្រឹក្សាលតាវល្លិស្មៅព្រៅ សូម្បីតែមួយដើមដុះនៅទីនោះសោះឡើយ ។ ដំណើរដែលនឹងដើរឆ្លងកាត់វាលខ្សាច់ធំធេងនោះទៅជាការលំបាកមិនតិចតួចទេ នឹងអាចឆ្លងកាត់ទៅបាន មានសត្វឱដ្ឋមួយពួកប៉ុណ្ណោះ ដែលជាសត្វអត់ធន់ជាងគេ ។ ចំពោះបាណ្ឌពក្សត្រិយ៍ ឃើញថាជាការលំបាក ជាងដើររុករុលក្នុងព្រៃ ទ្វេដប់ភាគទៅទៀត ព្រោះថាទ្រង់មានរាងកាយទន់ភ្លន់ល្វន់ល្វើយស្បើយកម្លាំងណាស់ ដោយដើរផ្លូវមកជាយូរថ្ងៃណាស់ហើយ កំដៅថ្ងៃសោតក៏ក្តៅដល់ទីទៀតផង នឹងដាក់ជើងជាន់លើស្ទើរពុំកើត ក្តៅជាងដើរក្នុងព្រៃប្រហែលដប់ភាគ ។ រស្មីព្រះអាទិត្យចែងចាំងមកត្រូវដុំក្រួស ឬថ្មតូច ៗ ក៏បែកចេញរស្មីឆ្លុះព្រាត ៗ ចាំងចូលក្នុងចក្ខុទ្វារបីដូចជាកញ្ចក់ ដែលត្រូវរស្មីព្រះអាទិត្យ ធ្វើឲ្យងងឹតព្រិលស្រវាំងភ្នែកដើរស្ទើរតែមិនរួចកំដៅធ្វើឲ្យទៅជាស្ងួតខះកស្រេកទឹក ឯរឿងទឹកផឹកក្នុងទីនោះវិញ កុំគិតរកល្អជាង ឥតឃើញហេតុឲ្យដឹងជាទំនងថា នឹងមានទឹកត្រង់កន្លែងណាសោះឡើយ ។ ទ្រង់សំគាល់ក្នុងព្រះទ័យថា ទ្រង់មុខជាដួលដាច់ខ្យល់ស្លាប់ក្នុងទីនោះមិនខានទេ ដ្បិតអស់ព្រះកាយពលល្វិតល្វៃពេញបន្ទុកមកហើយក្រែងនឹងលើកជើងឈានដើរទៅមុខទៀតពុំរួច ។ ដើមជ្រៃព្រឹក្សាដុះរុយ ៗ ខ្លះដែរនៅកន្លែងនោះ ប៉ុន្តែមិនជាទីត្រជាក់ត្រជុំដូចក្នុងព្រៃធំទេ ព្រះពាយបក់ផាត់ដោយទាំងកំដៅថ្ងៃមកផង ប៉ះត្រូវភក្ត្រដែល

ស្ងួតក្រៀម រីតតែក្រំក្រៀមណាស់ទៅទៀត ។ ទោះបីដល់ទៅម្ល៉ោះក្ដី ក៏ទ្រង់ចេះតែបបួលបងប្អូនព្យាយាមដើរឆ្លងវាលខ្សាច់ ឬហៅថា «ទន្លេខ្សាច់» ទៅទាល់តែព្រលប់ទៀបយប់អស្ដង្គត ។ វេលានោះ ទ្រង់បានឃើញអាស្រមមួយខ្នងតូច មានព្រៃឈើ និងស្រះទឹកថ្លានៅទិសខាងកើត ជាទីត្រជាក់ត្រជុំមនោរម្យសប្បាយ ល្មមនឹងបំបាត់ទុក្ខវេទនាដែលនឿយព្រួយមកតាមមាគ៌ា ឲ្យបានស្រាលស្បើយខ្លះ ទើបទ្រង់យាងចូលទៅរកទីនោះ សំចតនៅក្នុងអាស្រម ហើយអាស្រ័យទឹកក្នុងស្រះនោះ គ្រាន់នឹងរក្សាជីវិតទុកឲ្យរស់នៅតទៅមួយគ្រាសិន ។

អាស្រមនោះតាំងនៅក្នុងញកភ្នំហិមាល័យ ។ បាណ្ឌពក្សត្រិយ៍តាំងព្រះហឫទ័យនឹងអាស្រ័យនៅក្នុងអាស្រមនោះរហូត ១២ ឆ្នាំ តាមកំណត់ច្បាប់និរទេស ។ មានភ្នំទំនងជាបរិវារព័ទ្ធជុំវិញ សឹងពាសពេញទៅដោយព្រឹក្សាលតាជាតិផ្សេង ៗ ជាដង្ហុំដង្គោល ត្រសុំត្រសាយសាខា ហាក់ដូចជារយ៉ាំរយោលរយោនរយាន មានទាំងស៊ុមទ្រុមគុម្ពឈើ ស្លឹកស្លោមជិតងងឹតស្ងួន្យសុង មុខគួរឲ្យខ្លាចព្រឺព្រួចពោមា ព្រៃនោះឯងប្រាកដជាធម្មជាតិតាក់តែងឲ្យកើតឡើងយ៉ាងនេះ មិនដែលមាននរណាអាចហ៊ានឈានជើងដើរចូលទៅកាប់កាត់ព្រៃនោះសោះឡើយ ។ តាំងពីកាលណា ៗ មកហើយ មិនដែលឮសូរសម្លេងមនុស្សណាម្នាក់ ដើរចូលទៅវីវក្នុងមហាវននេះ



ដល់ម្ដងសោះឡើយ ។ រាល់តែរដូវ មើលទៅព្រៃព្រឹក្សានោះចេះតែល្អតលាស់ស្រស់ខៀវជាធម្មតាគួរជាទីស្នេហា នៃអ្នកដែលបានទៅយល់យល់ ឬម្យ៉ាងទៀត គួរហៅថាជាទីត្រជាក់ភ្នែក ក្នុងគិម្ហរដូវ ក៏មិនស្ងួតក្ដៅពេក ក្នុងហេមន្តរដូវ ក៏មិនសូវរងាណាស់ ប៉ុន្តែពេលស្រួលបំផុត គឺក្នុងវស្សានរដូវត្រូវភ្លៀងធ្លាក់ ជាទីត្រជាក់ត្រជុំជាងរដូវទាំងពួង ។ មេឃមីរបិទបាំងសុរិយាភាស រមែងឲ្យកើតស្រទំស្រទន់ត្រជាក់ អាកាសធាតុ ទាំងម្លប់ដោយស្លឹកព្រៃព្រឹក្សាជាតិអម្បាលនោះបាំងខាំងខ័ណ្ឌមួយជាន់ទៀត ក៏រឹតតែធ្វើឲ្យត្រជាក់ផែនពសុធាទ្វេឡើង មានទាំងទឹកសន្សើម និងទឹកភ្លៀងធ្លាក់ព្រើយ ៗ រ៉ុយ ៗ ប៉ប្រុយចុះមកប្រោះព្រំលើគុម្ពឈើតូចធំទាំងឡាយ តិណជាតិបានទទួលធាតុត្រជាក់នៃធម្មជាតិហើយ ក៏ល្អតលាស់ខៀវស្រស់រមឹតដេរដាសទាំងផ្ទៃធរណីមើលទៅគួរជាទីទស្សនា កលបីដូចជាព្រំចៀមធំ ដែលគេយកទៅលាតត្រដាងក្រាលទុកនៅទីនោះ ។ មានទាំងហ្វូងសត្វចតុប្បាទយំគឹកកងរំពងព្រៃ លាយច្រឡំទៅដោយសម្លេងបក្សីយំច្រេវច្រាវអឹងអាប់ទាំងដែនដងពនាល័យ ។ គន់ពីនេះទៅទៀត មានទាំងជ្រោះជ្រលងដងអូរ ផ្លូវទឹកហូរចុះទៅតាមចន្លោះថ្ម ឮសូរសន្ធឹកឈ្វ ៗ ឆ ៗ ទីខ្លះហូរចាក់ទៅប៉ះលើផែនសិលា ខ្ចាតគ្រាប់ទឹកប៉ប្រុយហុយជាផ្សែង ជួនកាលហូរបោះទៅលើផ្ទាំងថ្ម ហើយហូរចាក់ទៅភ្លាំង ៗ ភ្លុង ៗ ព្រោះខ្ទង់ជារំលុងរអាង ។ ផុតពីនោះទៅ ក៏ហូរសាច

រាចជ្រួតជ្រាបទៅតាមគុម្ពឈើ គល់ព្រឹក្សាទាំងឡាយ សម្រាប់ជប់ល្បើងព្រឹក្សាលតាជាតិទាំងពួង ឲ្យល្អល្អះខៀវស្រស់ជានិច្ចរាល់រដូវកាល ។ ឯព្រៃនោះជាទីលំនៅអាស្រ័យនៃទេព្រក្សទាំងឡាយ ជួនកាលមើលទៅប្រហែលហាក់រូបភាពចម្លងនៃនិរយភូមិ ជាទីពន្លឹកមុខគួរឲ្យស្ញប់ស្ញែងព្រឺព្រួច ក្នុងកមលហាឫទ័យយ៉ាងក្រៃលែង ។

នៅទីបំផុតនៃការពនេចរដើរព្រៃរបស់បាណ្ឌពក្សត្រិយ៍ ក៏ឈប់ស្លេះត្រឹមប៉ុណ្ណោះ ឃើញថាល្មមសមគួរតាមកតិកាសញ្ញានិរទេសហើយ ។ បាណ្ឌពក្សត្រិយ៍ បានអាស្រ័យនៅក្នុងព្រៃនោះ គ្រប់ ១២ ឆ្នាំតាមកម្រិតហើយ អាស្រ័យតែផ្លែឈើ, មើមឈើ, បន្លែព្រៃ និងសាច់សត្វ ដែលទ្រង់ថ្លែងសរបាន មកជាអាហារចិញ្ចឹមព្រះជន្ម ។ នាថ្ងៃមួយនោះ ក្នុងរវាងដែលនៅព្រៃ អរជុនភ្នកនឹកដល់រឿងដើម ទើបបញ្ចេញវចីភេទថា «ខ្ញុំនៅមានសេចក្ដីឆ្ងល់ថា មនុស្សណាម្នាក់ដែលក្រៀមក្រំ ទុក្ខទ្រមដូចយ៉ាងខ្លួនខ្ញុំខ្លះមានដែរឬទេ ? យើងព្រាត់ប្រាសចាកព្រះនគរ, ចាកចោលទ្រព្យសម្បត្តិ និងគណៈញាតិតូចធំទាំងឡាយ, រាល់ ៗ ថ្ងៃ ដែលកន្លងរំលងផុតទៅហើយ មានតែទ្វេសេចក្ដីសោកសៅរបស់យើង ឲ្យចេះតែពេញពោរកំពុងឡើង បីដូចជាចេះតែបន្ថែមទុក្ខសោកមកលើយើងពេញព្រៀបជានិរន្តរ៍, កាលទ្រៅបទីទេវីចូលទៅក្នុងទីប្រជុំហើយ ត្រូវគេចាប់សម្រាតសំពត់អាវនាង ផ្ចាញ់ផ្ចាលឲ្យយើងអាម៉ាស់មុខ ក្នុងទីចំពោះមុខអ្នកតូចអ្នកធំ



ទាំងពួង ការប្រមាថមើលងាយគ្នាក្នុងទីប្រជុំជនដូច្នេះ ឈ្មោះថាប្រមាថដោយក្លាហានណាស់ ហួសចិត្តស្ត្រីដែលពេញទៅដោយសេចក្ដីអៀនខ្មាស នឹងទប់ទល់បាន យ៉ាងទេវី នឹងទ្រាំបានដែរឬ ? អើម្ដេចក៏គ្រានោះ ខ្ញុំមិនក្របែលអាពួកកំណាចអស់នោះឲ្យខ្ទេចខ្ទីទៅ ? ឱអនិច្ចា ! ទាល់តែថ្មើរនេះហើយ បានរាវរកយករឿងដែលកន្លងហួសទៅហើយ នោះមកតំណាល តើនឹងមានប្រយោជន៍អ្វី ? »។

ភីមបានឮដូច្នោះហើយ ក៏ឆ្លើយឆ្លងឡើងថា «មិនតែប៉ុណ្ណោះទេ ក្ដារដែលលេងគ្នាគ្រាក្រោយបំផុតនោះ មិនមែនគ្រាន់តែធ្វើវិចារណញ្ញាណរបស់យើងឲ្យងងឹតទៅប៉ុណ្ណោះ វាថែមទាំងធ្វើចក្ខុរបស់យើងឲ្យងងឹតទៅទៀតផង, ក្នុងជាន់នោះ យើងឃើញផលអាក្រក់យ៉ាងច្បាស់ក្រឡែត ៗ យើងក៏នៅតែចចេសភ្នាល់នឹងគេទៀត ទាល់តែបោសរលីងធេងដូចជាគជ, ឥឡូវនេះនឹងបានជាផលប្រយោជន៍អ្វី ដែលយើងយំស្ដាយទឹកដោះកំពប់ខ្ចាយអស់នៅហើយ ? អើ ! ក៏កាលដែលខត្តិយរាជលើកលែងគ្រប់គ្រងសច្ចៈនិងធម្មៈសោះ ហើយបែរទៅប្រព្រឹត្តក្នុងបទដែលវិន័យហាមប្រាមមិនឲ្យប្រតិបត្តិវិញ ក៏បានឈ្មោះថាទ្រង់លើកលែងធ្វើជាក្សត្រិយ៍គ្រងរាជ្យ, កម្មប្រកាសមកថា «រាជសម្បត្តិ និងរាជអាណាចក្រនៃខត្តិយរាជនោះរមែងត្រូវគេរឹបយក, ទាំងខ្លួនខត្តិយរាជនោះសោត ក៏រមែងត្រូវអានុភាពនោះធ្វើទោស ឲ្យគ្រប់គ្រងជីវិតដោយសន្ដោស មានអាការៈដូចជាអ្នក

ទោសដែលលោកនិរទេស ឲ្យចេញទៅនៅព្រៃព្រោះហេតុតែល្បែង» រឿងត្រង់នេះ ក្នុងព្រះគម្ពីររបស់យើងបានចែងទុកថា «ការលេងល្បែងភ្នាល់ជាការបាប» មិនដូច្នោះទេឬ ? ឥឡូវនេះ យើងបានទទួលវិបាកនោះ សមតាមគម្ពីរពោលទុកមកមែនឬទេ ? យើងខូចបង់ព្រះនគរ, ខូចឥស្សរភាព, ខូចសព្វសារពើវត្ថុ គង់នៅសល់តែជីវិតដែលឥតកិត្តិយសប៉ុណ្ណោះ, យើងទៅអួតភ្នាល់នឹងគេឥតគំនិត អស់ប៉ុន្មានក៏អស់ទៅ ចេះតែកើបកោយចាក់ទៅទាល់តែរលីងក្រឹង ហ្នឹងហើយមកតែពីសេចក្ដីឆ្កួតរបស់យើងមិនមែនឬ ? ឥឡូវនេះយើងជាប់នៅក្នុងផុកផុងហើយមិនមែនឬ ? ប៉ុន្តែជារឿងរ៉ាវដែលកន្លងផុតទៅហើយ មិនគួរនឹងនាំយកមកនិយាយថ្វីទេ ឲ្យតែរវល់បែកពពុះមាត់ឥតអំពើសោះ, យើងធ្វើខ្លួនយើងមិនស្រួលឯង ៗ ឲ្យមនុស្សពេញលោកគេសើចឡកឡឺយបាន, យើងបន្ទាបខ្លួនចូលទៅលេងល្បែងស្កាទាល់តែចាញ់អស់ធនធានរលីងធេងហើយ ក៏នៅតែមិនស្កប់ស្កល់ ថែមទាំងព្រមសុខចិត្តឲ្យគេនិរទេសខ្លួន ព្រោះតែល្បែងនោះផងទៀត, សេចក្ដីសន្យាការនិរទេសពួកយើងនេះ វាធ្ងន់ខ្លួនណាស់ វាចងរឹតយើងមាំពេក ទាល់តែរើខ្លួនមិនរួច ស្មើដូចជាគេឲ្យមកស្លាប់ក៏ថាបាន»។

នកុលក៏បានស្ដាប់ភីមអភិប្រាយសព្វ ៗ ទៅ ក៏ទ្រង់ព្រះកន្សែងដោយគិតរំពឹងដល់ហេតុការណ៍ ដែលកន្លងទៅហើយនោះ និងហេតុ



ការណ៍ទៅខាងមុខទៀត ដែលនឹងត្រូវបានពើបប្រទះក្នុងថ្ងៃត ៗ ទៅ ទ្រង់ឈឺចិត្តជាទីបំផុត ទើបមានបន្ទូលថា «ឱ ! គ្រាគ្រោះថ្នាក់វិបត្តិសាត់មកដល់ បើទុកជាបុរសណាមួយឃុំគ្រងស្មារតីបាន គង់តែនឹងលោតចោលទូកដែលកំពុងលិចមុនរបស់ដទៃដែរ ប៉ុន្តែពេលនោះអស់ផ្លូវកែខៃ ហេតុភេទដែលកំពុងតែប្រព្រឹត្តទៅហើយ ប្រៀបលេងតែសាច់ឈាមរបស់គេ នឹងលះចោលមិនកើត »។

សហទេពឆ្លើយបន្ថែមមកទៀតថា «ឱព្រះ ! សម្លេងដែលទ្រៅបទីថ្វូរក្នុងបន្ទប់ប្រជុំរដ្ឋមន្ត្រីនោះ វានៅតែឮជាប់នឹងត្រចៀកខ្ញុំដល់សព្វថ្ងៃនេះ ព្រះទេវីត្រាស់ត្រូវតាមច្បាប់ហើយថា «ព្រះរាជស្វាមីរបស់នាងធ្លាក់ទៅក្នុងឋានៈជាទាសាហើយ រមែងគ្មានអំណាចតាមផ្លូវច្បាប់ដែលនឹងលក់នាង ឬនឹងយកនាងទៅដាក់ភ្នាល់, ហេតុម្ដេចក៏យើងមិនលើកយកច្បាប់នេះមកជជែកតវ៉ា ហើយសូមឲ្យដំណើរការទៅតាមច្បាប់នោះ ? ប៉ុន្តែគ្រានោះ កំពុងជ្រួលច្របល់ទាំងគេទាំងឯង គ្មានអ្នកណានឹកឃើញទាន់ រវល់តែទៅគិតអាណិតនាងគ្រប់ ៗ គ្នា, អ្នកតូច អ្នកធំ បណ្ដាដែលនៅក្នុងទីប្រជុំជននោះជាច្រើននាក់ អត់ទ្រាំមិនបាន ក៏ស្រក់ទឹកភ្នែកតាម ៗ គ្នា ប្រៀបលេងតែទុរយោធន៍ម្នាក់ឯងប៉ុណ្ណោះ, ខ្ញុំចង់ដឹងណាស់ថា ចិត្តថ្លើមរបស់វាដូចម្ដេចទៅអេះ ? »។

យុធិស្ឋិរអង្គុយស្ដាប់អនុជទាំង ៤ អង្គសន្ទនាគ្នា រហូតមកដល់

វេលានេះ ដោយទ្រង់មិនចង់យល់ទាស់សោះ ប៉ុន្តែខំអត់មិនបាន ទើបផ្ដាយចេញជាព្រះបន្ទូលជាផ្លូវប្រលោមចិត្តប្អូនថា «ណ្ហើយកុំ! កុំតូចចិត្តថ្វី ! យើងបានស្បថទុកហើយថា «នឹងធ្វើការកំហឹងវិញឱ្យទាល់តែបានសម្រេចផល» ក្នុងឋានៈនៃក្សត្រិយ៍ យើងត្រូវតែប្រតិបត្តិការឱ្យសមតាមពាក្យ ដែលបានសច្ចាប្រណិធានទុកមករាល់ម៉ាត់, ទាំងនេះព្រោះតែកម្មរបស់យើង យើងត្រូវតែទទួលសោយទុក្ខវេទនាទាំងនេះទៅចុះ យើងចៀសវាងគេចចេញទៅឯណា ក៏មិនរួចដែរ, របស់ដែលត្រូវវិបត្តិ ក៏ត្រូវតែវិបត្តិទៅជាមិនខាន, របស់ដែលវិបត្តិហើយសោត ក៏បានវិបត្តិរួចទៅហើយ, មុខងាររបស់យើងវេលានេះមានតែចៀសវាងភយន្តរាយ លាក់ខ្លួនពួនមុខ ទៅតាមសេចក្ដីសន្យាបន្តិចទៀតតែប៉ុណ្ណោះ, សេចក្ដីលំបាកតោកយ៉ាករបស់យើង ក៏ស្រាលស្បើយអស់ហើយ» ។

កិច្ចសន្យាដែលបាណ្ឌពក្សត្រិយ៍ ត្រូវប្រតិបត្តិនៅវេលានេះឈ្មោះថា ផុតអស់ហើយ នៅតែត្រង់លាក់ខ្លួនអាត្មាឲ្យផុតភ័យ រក្សាខ្លួនទុកឲ្យបានគង់ លុះគិតឃើញយ៉ាងនេះហើយ បាណ្ឌពក្សត្រិយ៍ភាតា ក៏នាំគ្នាផ្លាស់ប្ដូរទីកន្លែងជាញឹយ ៗ ទៅ ចេញពីទីនេះ ទៅនៅទីនោះ ដូចជាមនុស្សកំសត់ទុគិតដើរដេកដោយព្រៃក៏ប្រហែលគ្នា ។ ការដែលត្រាច់ពនេចរទៅដូច្នេះ រមែងមានភ័យនៅជុំវិញខ្លួន តែងនឿយព្រួយលំបាករូបកាយជាធម្មតា ព្រោះមានសភាពតាមធម្មតា



របស់រូបកាយតែងអន្ទោលទៅតាមខ្លួនប្រាណដូចស្រមោល នឹងចៀសវាងឲ្យផុតទៅមិនបានទេ គឺត្រូវកំដៅថ្ងៃ, សេចក្ដីក្រហល់ក្រហាយ ស្រេកទឹក ឃ្លានបាយ សេចក្ដីនឿយព្រួយព្រះកាយពលព្រះបាទាដែលធ្លាប់តែទន់ភ្លន់ត្រសុសត្រសូល ក៏ប្រែខ្វៃទៅជាព្រោះគ្រិនពុរពង បន្លាមុត ជល់ជំពប់ប៉ះបែកចេញលោហិត របស់ទាំងនេះជាទុក្ខវេទនារាល់គ្រាដែលទ្រង់នាំគ្នាត្រាច់សញ្ចរពីត្រង់ណោះទៅត្រង់ណោះ ។

វារៈមួយនោះ ទ្រង់យកអាវុធសម្រាប់អង្គទៅលាក់ទុកលើមែកឈើ ហើយនាំគ្នាចូលទៅកាន់ក្រុងវិរាជ ដើម្បីនឹងលាក់ខ្លួនពួនអាត្មានៅក្នុងក្រុងនោះឲ្យផុតចាកភយន្តរាយ ។ ព្រោះហេតុថា កិច្ចសន្យាការនិរទេសបានបញ្ញត្តិទុកថា «បើពួកកោរពបានជួបប្រទះឃើញខ្លួនក្នុងរវាងពេលសន្យានេះសោត ពួកបាណ្ឌពត្រូវតែត្រឡប់ទៅដើរព្រៃសាជាថ្មីវិញ កំណត់អស់រយៈកាល ១២ ឆ្នាំទៀត» កតិកាត្រង់នេះពួកបាណ្ឌពត្រូវប្រតិបត្តិ និងត្រូវប្រុងប្រយ័ត្នអង្គឲ្យមែនទែន ឲ្យទៀងទាត់តាមសន្យា ។

## ភាគទី ៨

# ព្រះរាជាក្រុមខរាជ

សម័យមួយ ព្រះបាទវិរាជគង់លើរាជាសនៈ ក្នុងព្រះទីនាំងវិនិច្ឆ័យ មានអាមាត្យមុខមន្ត្រីបង្គំគាល់ត្រៀបត្រា ទ្រង់ព្រះសណ្តាប់ដីកា និងពាក្យស្រែកថ្លែងទុក្ខរបស់បណ្តារាស្ត្រ, កំពុងតែទ្រង់វិនិច្ឆ័យឲ្យទៀងទាត់សុចរិតទៅតាមយុត្តិធម៌ដល់ពួកដែលត្រូវគេបៀតបៀន ។ ខណៈនោះទ្រង់ទតទៅឃើញប្រុសប្អូនប្រាំនាក់តែងកាយយ៉ាងចាស់ក្រាំគ្រារឃីករយាកឈរនៅក្បែរទ្វារព្រះរាជវាំង ទើបមានព្រះរាជឱង្ការឲ្យរាជភ័ដម្នាក់ទៅសាកសួរថា អ្នកទាំងនោះជាអ្នកណា ? មកមានការអ្វី ? កាលបានទ្រង់ព្រះសណ្តាប់សេចក្តីនោះហើយ ត្រាស់ឲ្យហៅចូលមកដល់មុខព្រះទីនាំង ទ្រង់ព្រះរាជទានឱកាសឲ្យគេក្រាបទូលសេចក្តីដល់ព្រះអង្គតាមការណ៍ពិតត្រង់ ។ គ្រានោះ អង្គមួយក្នុងពួកបងប្អូនទាំង ៥ បានក្រាបទូលថា «គ្រោះអាក្រក់មុខគួរឲ្យស្ញែងដែលបានឧប្បត្តិឡើងដល់មហារាជយុធិស្ឋិរប្រហែលជាបានជ្រាបដល់ព្រះអង្គរួចហើយ ឯគ្រោះថ្នាក់របស់ពួកទូលព្រះបង្គំជាខ្ញុំនេះជាភាគមួយក្នុងព្រះគ្រោះនោះដែរ គឺពួកទូលព្រះបង្គំជាខ្ញុំរាជការនៃមហារាជយុធិស្ឋិរ កាលព្រះអង្គត្រូវគេនិរទេសចេញពីព្រះនគរហើយ ពួកទូលព្រះបង្គំក៏រងាក្នុងចិត្ត ដ្បិតគ្មានទីពឹង



ពាក់ ទើបត្រាច់ស្វែងរកចៅហ្វាយនាយដ៏សមគួរឲ្យបានជាទីពឹងពាក់តទៅ បានឮព្រះកិត្តិគុណរបស់ព្រះអង្គ ដែលទ្រង់អើពើណាស់នោះ ទៅដឹកនាំពួកទូលព្រះបង្គំឲ្យបានមកដល់ទីក្រុងនេះ ពួកទូលព្រះបង្គំមានបំណងនឹងមករកសុំមុខការធ្វើក្នុងព្រះរាជសំណាក់ណាមួយ តែគ្មានព្រះរាជាអង្គណាទទួលយកសោះ ចេះតែបដិសេធរាល់នគរ ក្នុងទីបំផុតបានមកដល់ក្រុងនេះ ពួកទូលព្រះបង្គំសូមប្រគល់កាយថ្វាយជីវិតចំពោះព្រះអង្គ សូមជ្រកកោនក្រោមម្លប់ព្រះពោធិសម្ភារបារមីតទៅ» ។

ព្រះរាជាបានទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏ស្លុតព្រះហឫទ័យពន់ប្រមាណ បែរព្រះភក្ត្រទៅខាងសេនាបតី មានព្រះរាជតម្រាស់ថា «ការនិរទេសយុធិស្ឋិរ ដោយផ្លូវអយុត្តិធម៌នេះ ធ្វើឲ្យយើងជារាជសម្ព័ន្ធមិត្រនឹងទ្រង់ កើតទុក្ខទោមនស្សយ៉ាងខ្លាំង ហើយធ្វើឲ្យបណ្តារាស្ត្រពាសពេញផែនដី បានសេចក្តីព្រួយលំបាកជាអនេករាស្ត្រមានចំនួនរាប់ពាន់នាក់នាំគ្នាត្រឡប់ត្រឡិន ប្រឡូកប៉ូកប៉ាកព្រាត់ចាកទីលំនៅ មកពីម្ចាស់របស់គេត្រូវនិរទេសទៅនៅព្រៃហើយ, សេចក្តីវក់របស់ទុរយោធន៍នេះ នឹងនាំមកនូវសេចក្តីវិនាសដល់ខ្លួនជាមិនខាន, យើងនឹងបដិសេធចោលពាក្យសុំអស់អ្នកនេះមិនបានទេ គេមិនមែនមកសុំទានយើងកាលណា គេសុខចិត្តមករកសុំការធ្វើ, រឿងនេះសម្តែងឲ្យឃើញច្បាស់ថា គេមិនមែនជាស្មូមយាចក

ដើរសុំទានគេតាមថ្នល់ទេ អ្នកទាំងឡាយចូរទទួលគេទុកសម្រាប់ ឲ្យគាល់បម្រើយើងចុះ » ។

បាណ្ឌពក្សត្រិយ៍ព្រមព្រៀងគ្នាធ្វើវន្ទនាការ ចំពោះព្រះរាជាហើយ ក៏ថយចេញមកអំពីមុខព្រះទីនាំង ។ តអំពីនោះមកមួយស្របក់ មានស្ត្រីម្នាក់តែងកាយរយីករយាកដើរចូលទៅក្នុងអន្តេបុរដ្ឋាន (ព្រះរាជវាំងជាន់ក្នុង) ឯទម្រង់រូបឆោមល្អឥតខ្ចោះ បើអ្នកណាបានឃើញហើយ ក៏កើតចិត្តប្រតិព័ទ្ធស្នេហានឹងឆោមឆើតរបស់នាងស្ទើរតែភ្លាំងភ្លេចស្មារតី ។ ព្រះរាជិនីព្រះបាទវិរាជត្រាស់សួរថា នាងជាអ្នកណា ? នាងមករកអ្វី ?

- ខ្ញុំម្ចាស់ជាស្ត្រីកំសត់ទុគ៌ត ឥតទីពឹងសោះ មានតែសេចក្ដីទុក្ខព្រួយប្រាណស្ទើរប្រេះទ្រូងស្លាប់ ។

- ចុះនាងឈ្មោះអ្វី ?

- ខ្ញុំម្ចាស់ឈ្មោះថា «សៃរិន្ទ្រី» នាងក្រាបទូលដោយសម្លេងថ្នម ៗ ។

មើលទៅព្រះភគ្គរានី (ព្រះរាជិនី) អង្គុយឲ្យឃើញថាទ្រង់មេត្តាប្រោសប្រណីដល់នាងជាពិតប្រាកដណាស់ ឯលំអរូបឆោមរបស់នាងយ៉ាងត្រចះត្រចង់ ទាំងកិរិយាមារយាទ ក៏របៀបរយឥតខ្ចោះ សមជាអ្នកមានត្រកូលឧត្ដមពង្ស ប៉ុន្តែមើលទៅបែបដូចជាមនុស្សកើតទុក្ខ មុខស្លក់ស្លាំង បែរមើលទៅលក្ខណាល្អអស្ចារ្យធ្វើឲ្យរានីនឹក



ឆ្ងល់ណាស់ ទើបត្រាស់សួរថា «រូបរាសីរបស់នាងល្អដល់ម្ល៉េះ ម្ដេចក៏មិនកំចាត់បង់ភ័យឧបទ្រពឲ្យឃ្លាឃ្លាតចេញទៅ ? » ។

ឱព្រះម្ចាស់ ! ព្រះនាងទ្រៅបទី ទ្រង់នូវរូបសម្បត្តិឆើតឆាយរកស្ត្រីណាមួយក្នុងលោកប្រៀបផ្ទឹមឲ្យស្មើគ្មាន ម្ដេចក៏គង់តែត្រូវគ្រោះកម្មនាំឲ្យស្ដេចទទួលឧបទ្ទវន្តរាយ ត្រូវស្ដេចព្រាត់ព្រាកចាកព្រះនគរ និងសិរីរាជ្យសម្បត្តិ កាលបើលើកយកព្រះនាងនោះមកធៀបនឹងរូបខ្ញុំម្ចាស់ ដែលគ្រាន់តែទាសីរបស់ព្រះទេវីប៉ុណ្ណោះមិនបាច់សង្ស័យក្នុងរឿងនេះឡើយ » ។

ព្រះរានីត្រាស់សួរតទៅទៀតថា «ចុះនាងត្រូវការរបស់អ្វី ?» ។

ខ្ញុំម្ចាស់មករកសុំការណាមួយធ្វើ គ្រាន់នឹងបានចិញ្ចឹមជីវិតតទៅ ។

- នាងសុខចិត្តនៅបម្រើយើងឬទេ ?

សៃរិន្ទ្រីសុខចិត្តទទួលធ្វើនាទីនោះដោយគុណ្ណភាព ហើយថ្វាយបង្គំលាថយទៅនៅក្នុងបន្ទប់ពួកខ្ញុំរាជការស្ត្រី ។

គ្រានេះ យើងនឹងបានឃើញបន្ទប់ទីបន្ទំរបស់រានី, នៅវេលារាត្រីយាមយប់សន្ធ្យា ក្នុងបន្ទប់ព្រះទេវីអុជប្រទីបថ្វាលាភ្លឺព្រោងព្រាយ ធុំក្លិនពិដោរឈ្ងុយឈ្ងប់សព្វសាយទៅដោយប្រេងក្រអូបដែលអុជនោះទូទាំងល្វែងព្រះមន្ទីរ, ជញ្ជាំងបន្ទប់ព្រះដំណាក់ធ្វើដោយមោរ៉ាសិលាពណ៌ ថ្មីដែជាងដ៏វិចិត្រយ៉ាងឯក ឆ្លៅឆ្លុះរស្មីរលង់

រលើបរលីងស្រិលព្រិលនេត្រា, ព្យួររំយោលរយ៉ាដែលថ្មីដៃប៉ាក់ជារូបផលាផល និងទងភ្ញីវល្លិរស់រវើក មុខគួរឲ្យមៀងមើលត្រកាលភ្នែកណាស់ និងតុបតែងគ្រឿងតាំង ដ៏មានតម្លៃដទៃទៀតជាច្រើនបែបយ៉ាង ។ ឯទីផ្ទៃព្រះដំណាក់ក្រាលដោយសិលាទន់ ហើយក្រាលព្រំចៀមដ៏ទន់ល្មើយត្រជាក់ជើង មានជាយប៉ាក់ចាក់ចំដោយខ្សែសយមាសប្រាក់, មានព្រះទែនភ្លុកដ៏ចំព្លែងចិញ្ចាចជាសពាសសំពត់ព្រៃតាំងនៅកណ្តាលបន្ទប់នេះ ។ សៃរិន្ទ្រីតែងចេញចូលគាល់បម្រើព្រះទេវីដល់ក្នុងបន្ទប់នេះរាល់វេលា ។ ក្នុងបន្ទប់មួយទៀត មានរបៀបប្រហែលគ្នាដែរ ។ កិច្ចកៈព្រះអនុជរបស់រានី កំពុងផ្ទំក្រៀមក្រំដាលដំក្នុងឱរាជាទម្ងន់ ជួនកាលក៏ថ្ងូររវើរវាយ ជួនកាលក៏ដកដង្ហើមធំឮសូរឃូរ ។ ព្រះជេដ្ឋភគិនី (រានីព្រះបាទវិរាជ) គង់ទៀបព្រះទែនភ្លុកយកព្រះហស្តស្ទាបព្រះនលាអនុជដើម្បីរម្ងាប់សេចក្តីឈឺចាប់ ឲ្យធូរស្បើយទៅខ្លះ ប៉ុន្តែមិនបានស្បើយល្ហើយតាមសេចក្តីនឹកសោះ ។ លំដាប់នោះ ព្រះអនុជទ្រង់កន្ទ្រៀងអាក់អួល ហើយមានបន្ទូលថា «ម្ចាស់បងប្រហែលជាចោលប្អូនឲ្យស្លាប់បង់តែឯកឯងហើយឬ ?»។

- មិនមែន, មិនមែនទេប្អូន ! បងលេងនិយាយនឹងប្អូនឯងទៀតហើយ បើឯងនិយាយព្រើល ៗ យ៉ាងនេះ អ្វីមកបញ្ចូលចិត្តឯង ឲ្យនឹកដល់មច្ចុរាជយ៉ាងនេះ ? ប្អូនឯងប្រឈួនបន្តិចបន្តួចប៉ុណ្ណោះទេតើមិនប៉ុន្មានថ្ងៃទេ មុខជានឹងសះជាតាមប្រក្រតី ឡើងវិញហើយ ។



- កុំគប្បីនឹកដូច្នោះឡើយ ម្ចាស់បង ! អាការៈរោគរបស់ប្អូនគ្រានេះ មិនមែនតិចតួចដូចម្ចាស់បងសំគាល់នោះទេ សមុដ្ឋានរោគនៅក្នុងចិត្ត ហើយនឹងដែលបាត់ទៅវិញបានដោយហេតុពីរយ៉ាងណាមួយ គឺស្លាប់បង់ ឬក៏ ...... ។

រានីត្រាស់កាត់សំនួនពាក់កណ្តាលឡើង ថា «ទៀតហើយ ! ទៀតហើយ ! ប្អូនឯងនិយាយចេញឈ្មោះសេចក្តីស្លាប់ទៀតហើយ មិនចង់ស្តាប់ពាក្យប្អូនឯងទេ»។

-ល្អហើយ, ថាបើដូច្នោះ ទូលបង្គំត្រូវធ្វើមុខក្រាស់ល្បងមើលតែម្ចាស់បងប្រទានទោសរឿងមុខក្រាស់នោះ ទូលបង្គំនឹងទូលរឿងដែលពិត ហើយនឹងបញ្ចេញសេចក្តីស្ងាត់កំបាំងនៃអាការៈរោគក្នុងខ្លួនឲ្យទ្រង់ជ្រាប ។

- សេចក្តីស្ងាត់កំបាំងដូចម្តេច ប្រុសអើយ ?

- ម្ចាស់បងប្រទានទោសដល់ទូលព្រះបង្គំ ឬ ?

រានីនឹកឆ្ងល់ណាស់ មិនដឹងបើមានព្រះសវនីយ៍ថាដូចម្តេច ? ព្រះនាងសព្វព្រះទ័យថា ចិត្តអនុជវវើកនឹងសេចក្តីឈឺចាប់ មានសតិវិបល្លាសនិយាយរវើរវាយផ្តេសផ្តាស, ព្រះនាងទ្រង់សន្និដ្ឋានថា សមុដ្ឋានអាការៈប្រឈួននៃព្រះអនុជ មុខជាកើតមកពីការរញ៉ីករញ៉ុក ឬសេចក្តីខឹងរអែរអូវ ស្ទើរតែបន្តិចបន្តួចក៏ដរធរទៅជាធំដុំឡើងបាន អាចធ្វើឲ្យអ្នកជំងឺមានអាការៈរោគកាន់តែធ្ងន់ព្យេបទៅ

ទៀតបាន, ព្រះនាងទ្រង់ព្រះតម្រិះថា គួរតែអញលួងសួរយកសេចក្ដីពិតពីអនុជឲ្យបាន រឿងដែលអនុជនឹងធ្លាយចេញមកនោះ ជារឿងមានសារប្រយោជន៍ ឬគ្មានដូចម្ដេចក៏តាមការចុះ ការដែលលួងលោមសួរយកសេចក្ដីពិតដូច្នេះ មិនជាការទាស់ខុសអ្វីទេ ។ ព្រះនាងទើបត្រាស់ប្រលោមដោយព្រះសូរសៀង ដ៏ស្រទន់ផ្អែមល្ហែមថា «កិចកៈ បាឯងឈឺអ្វី ប្អូនសម្លាញ់បង ? ចូរប្រាប់បងឲ្យសព្វគ្រប់មកមើល» ។

កិចកៈក៏បញ្ចេញសេចក្ដីស្វាត់កំបាំងក្នុងចិត្តថ្វាយព្រះនាងបងទ្រង់ព្រះសណ្ដាប់ដោយឥតអៀនខ្មាសថា «ឆោមល្អស្រស់នៃនាងសៃរិន្ធរីស្ត្រីបម្រើម្ចាស់បងបានចូលមកសន្ធំសម្ងំនៅក្នុងចិត្តទូលព្រះបង្គំទាំងថ្ងៃទាំងយប់ ។ ការដែលនាងប្រើចុងភ្នែកក្រឡេកមើលម្ដង ៗ ធ្វើឲ្យទូលបង្គំចាប់ចិត្តប្រតិព័ទ្ធឥតភ្លេចមួយវេលា តាំងពីគ្រាដែលបានឃើញវរភក្ត្ររបស់នាងមករហូតដល់វេលានេះ ទូលបង្គំពេញទៅដោយសេចក្ដីទុក្ខក្ដុកក្ដួលអួលណែនក្នុងឱរា ដោយហេតុត្រូវកាមសររបស់នាង ។ កិចកៈទូលប៉ុណ្ណោះហើយ ក៏បណ្ដាលចិត្តអាក់អួលឆ្អួលឡើង ទឹកព្រះនេត្រស្រក់តក់ ៗ » ។

រានីឃើញព្រះអនុជទ្រង់កន្សែង ក៏សព្វព្រះទ័យថា នេះព្រោះតែសេចក្ដីស្នេហា ស្រឡាញ់មកគ្របរួបរឹតដួងចិត្តអនុជ, ព្រះនាងក៏ទ្រង់ដាស់តឿនអនុជពីរឿង ដែលចាប់ចិត្តស្រឡាញ់ទៅលើរូបស្ត្រី



មិនគួរគប្បីជាហេតុនាំឲ្យកើតសេចក្ដីអប្បយសថា «ចុះបាឯងមិននឹកឃើញដល់សេចក្ដីថោកទាបកិត្តិយស និងវង្សត្រកូល ដោយហេតុបន្ទាបបន្ថោកខ្លួនទៅផ្ដេកផ្ដិតនឹងនាងទាសីនោះឬទេ ? បាឯងធ្វើកេរ្ដិ៍ឈ្មោះដ៏ល្អនៃបុព្វបុរសរបស់ខ្លួនឲ្យសាបសូន្យទៅ ថែមទាំងធ្វើឲ្យកើតសេចក្ដីអប្បយសដល់ខត្តិយវង្ស ដ៏ឧត្តមស័ក្ដិផងទៀតដោយសារត្រូវនាងទាសីពត់ទាល់តែវរវីកវិលខួរអស់, ការញញឹមញញែម ឬចោលកន្ទុយភ្នែកនោះជាសម្បត្តិរបស់ស្ត្រីអ្នកលែងទេតើ, ចូរអ្នកត្រួតត្រាមើលឲ្យល្អល្អិតជាមុនសិន ដ្បិតមានពាក្យចាស់ផ្ដាំទុកមកថា «កុំបីទុំស៊ុនមុនស្រគាល កុំបីអាលគ្រុនមុនជំងឺ» រឿងនេះជាការអប្រិយបំផុត មិនគួរប្រថុយប្រាណទៅផ្ដេកផ្ដិតទេ, សេចក្ដីស្រឡាញ់រមែងមានរាល់រូប អ្នកណាគេឃាត់មិនឲ្យស្រឡាញ់ ? ប៉ុន្តែត្រូវស្រឡាញ់ឲ្យគួរគប្បីផង, ឯលោហិតប្រុសកំលោះកំពុងពេញពាលច្រើនតែធ្វើឲ្យកើតសេចក្ដីវឹកវរឡើងក្នុងចិត្ត ដោយមិនត្រិះរិះត្រួតត្រាឲ្យសព្វគ្រប់ នេះជាហេតុឲ្យខូចខាតសម្មានស័ក្ដិនៃរាជត្រកូល និងជាមន្ទិលសៅហ្មងដល់ពួកគណៈផង » ។

ទូលបង្គំដឹងរឿងរ៉ាវអស់នេះសព្វគ្រប់រួចហើយ ប៉ុន្តែប្រហែលម្ចាស់បងនៅពុំទាន់ទ្រង់ជ្រាបមរណកាលរបស់ទូលបង្គំ ដែលវាចូលមកជិតណាស់ហើយនោះទេ, បើម្ចាស់បងមានបំណងឲ្យទូលបង្គំស្លាប់ ឬនឹងល្បងមើលចិត្តទូលបង្គំសោត មិនចាំបាច់ម្ចាស់បងលើក

យកបរមត្ថចរិយាមកទេសនាច្រកត្រចៀកមនុស្សដែលជិតដាច់ខ្យល់ស្លាប់យ៉ាងនេះទេ» កិច្ចកៈឆ្លើយ ។

«សេចក្តីបំណងរបស់បងប្រុងតែនឹងជួយប្អូនឲ្យផុតអំពីការអប្បយសអាម៉ាស់មុខ ទាំងនេះជាប្រាកដ ប៉ុន្តែបងតូចចិត្តណាស់ប្អូន ! ត្រង់ការដែលប្អូនយល់ឃើញសណ្ឋាវាចាពាក្យដាស់តឿនរបស់បងថា មានតែបក់ភ្លើង គឺសេចក្តីឆ្កួតតណ្ហារបស់ឯងឲ្យឆេះពាលរាលរឹតតែខ្លាំងឡើងទៅវិញ ហាក់ដូចជាបងមកញុះប្អូនឯងឲ្យដើរទៅកាន់ផ្លូវវិនាសកម្ម ប៉ុន្តែបើចេតនារបស់ប្អូនប៉ុនប៉ងនឹងយកស្ត្រីនោះឲ្យបាន ឬនឹងស្លាប់នោះ យើងជាបងនឹងបណ្តោយឲ្យប្អូនស្លាប់ដូចម្តេចកើត ត្រូវតែជួយជ្រោមជ្រែងឲ្យរួចរស់ជីវិតទៅសិន វៀរលែងតែរឿងនេះផុតហួសវិស័យរបស់បង» រានីត្រាស់ប៉ុណ្ណេះហើយ ក៏ស្តេចចេញពីបន្ទប់នោះ មានសវនីយ៍ឲ្យហៅនាងស្នំសៃរិន្ទ្រី ។ សៃរិន្ទ្រីចូលមកគាល់ឈរចំពោះមុខព្រះទីនាំងចាំស្តាប់ព្រះសវនីយ៍ ។ រានីឃើញនាងចូលមកគាល់ហើយ មិនត្រាស់ថាអ្វី ទ្រង់គង់ស្ងៀមព្រងើយ ដូចជាមានសេចក្តីមួហ្មងក្នុងព្រះទ័យម្យ៉ាង ប៉ុន្តែតាមពិត ព្រះនាងកំពុងតែរិះគិតរកប្រយោគនឹងត្រាស់ប្រាប់ ព្រោះជារឿងអាថ៌កំបាំងល្អិតសុខុម និងជារឿងមុខគួរឲ្យអៀនអន់, ព្រះនាងជញ្ជីងរកផ្លូវប្រហែលមួយស្របក់ ទើបត្រាស់ថា «មុខគួរឲ្យស្តាយណាស់ ដែលឃើញកន្យាអ្នកឧត្តមសម្បូណ៌ដោយគុណសម្បទយ៉ាងនាង ហើយមកធ្លាក់



ខ្លួនទៅជាទាសីសម្រាប់បំរើគេក្នុងផ្ទះដូច្នេះ» ។

«នេះជាកុសលកម្មរបស់ខ្ញុំម្ចាស់ វាតាមមកស្នងផល» សៃរិន្ទ្រីទូលឆ្លើយ ។

- «យើងឃើញច្បាស់ថា នាងឯងមិនជាស្ត្រីធម្មតាទេ ព្រោះមានសរសៃក្រសៃលោហិតខៀវច្រើន ស្មើនឹងសរសៃលោហិតរបស់យើង ល្អហើយនាងមុខជាមានចិត្តត្រេកអរនៅវេលាដែលនាងបានឮថា អនុជរបស់យើងមានសេចក្តីស្នេហាស្រឡាញ់នាងឯង ហើយខ្លួនយើងក៏មានចិត្តត្រេកអរផងដែរ ដោយបានឃើញនាងធ្វើបាទបរិចារិការបស់អនុជ» រានីត្រាស់ ។

ព្រះតម្រាស់របស់រានីនេះមិនធ្វើឲ្យសៃរិន្ទ្រី កើតសេចក្តីត្រេកអរ ឬក៏នឹកស្ងើចអស្ចារ្យក្នុងចិត្តសោះឡើយ ត្រឡប់ជាធ្វើឲ្យនាងក្រេវក្រោធពិរោធហាក់ដូចអគ្គីត្រូវពាយុ ទើបតបព្រះសវនីយ៍ថា «វាអាម៉ាស់មុខណាស់ព្រះរាជិនី ! សម្តេចព្រះមេម្ចាស់មិននឹករឿងនេះផង, ខ្ញុំម្ចាស់មិនបានគិតនឹកនាសោះឡើយថា ព្រះមេម្ចាស់នឹងបន្ទាបបន្ថោកព្រះអង្គចុះមកលេងក្នុងរឿងដ៏អប្រិយនេះ ដែលមនុស្សជាផងទាំងពួង គេមិនដែលនិយាយ ឬមិនធ្លាប់ប្រព្រឹត្តមកសោះឡើយ, ខ្ញុំម្ចាស់ទើបតែនឹងបានដឹងឮក្នុងវារៈនេះជាដំបូងថា «ស័ក្តិខ្ពស់ និងកេរ្តិ៍ឈ្មោះនោះ» វាមិនដែលជាប់នៅជាមួយគ្នាជានិច្ចទៅទេ, ព្រះមេម្ចាស់ ប្រហែលជាមិនដែលបានជួបប្រទះឃើញនារីដែលស៊ូប្តូរលុះ

បង់ជីវិតរបស់ខ្លួនដើម្បីការពាររក្សាកិត្តិយស ទុកឲ្យគង់ទេមើលទៅ, ប្រហែលជាទ្រង់ធ្លាប់ជួបប្រទះតែនឹងស្ត្រី ដែលគ្រាន់តែឮសូរសម្លេងប្រាក់ក្រឹង ក៏ញញឹមដាក់ភ្លាម ហើយបណ្ដាលឲ្យបានសម្រេចដូចប្រាថ្នាមួយរំពេចទៅ, ឯខ្ញុំម្ចាស់គ្មានសំដីអ្វីឡើយ ដែលនឹងក្រាបទូលឲ្យច្រើនជាងនេះទៅទៀតទេ មានតែពាក្យបញ្ចប់សំដីដើមបន្តិចទៀតថា «តាំងពីនេះជាដើមទៅ ខ្ញុំម្ចាស់លែងធ្វើជាខ្ញុំស្រីគាល់បម្រើព្រះមេម្ចាស់តទៅទៀតហើយ, ខ្ញុំម្ចាស់មានអំណាចនឹងចង់ទៅណាក៏ទៅបានតាមចិត្ត» ។

រានីត្រាស់ជាប្រញាប់ថា «កុំតូចចិត្តថ្វីឡើយនាង! ចូរនាងអត់ទោសដល់យើងទៅចុះ, ចូរនាងបំភ្លេចពាក្យដែលយើងនិយាយអម្បាញ់មិញនេះឲ្យបាត់សូន្យទៅចុះ, នាងកុំខឹងសម្បាអ្វីឡើយ ចូរយកកែវសុរានេះទៅថ្វាយកិច្ចកៈ ប្រហែលជាចាំមើលផ្លូវនាងផ្សាភ្អែកហើយ » ។

រានីសំគាល់ថា ដែលសៃរិន្ទ្រីសម្ដែងអាការក្រេវក្រោធយ៉ាងហ្នឹងជាមាយាស្ត្រីទេតើ, ព្រះនាងឥតសង្ស័យសោះ ហើយជឿជាក្នុងព្រះទ័យថា សៃរិន្ទ្រីមុខជាត្រេកអរក្នុងរឿងដែល កិច្ចកៈមានប្រតិព័ទ្ធស្នេហានឹងខ្លួនជាប្រាកដ ហើយទុកចិត្តថា នាងមុខជាត្រេកអរនឹងនាំយកកែវសុរាទៅថ្វាយកិច្ចកៈ ។ ឯសៃរិន្ទ្រីបានយល់ច្បាស់ថា សុរាមួយកែវនេះ ជាឧបាយដើម្បីធ្វើហេតុឲ្យសមទៅតាមផល ធ្វើឲ្យអ្នក



ទាំងពីរ គឺខ្លួននាង និងកិច្ចកៈបានជួបគ្នាស្ងាត់ៗ, ក្នុងជាន់ដំបូងនាងគិតរារែក លុះនាងគិតម្ដងទៀត ក៏ព្រមទៅដោយតាំងព្រះទ័យជាប់ក្នុងកុសលរាសីជាកម្លាំងសម្រាប់តទល់ នឹងអាការៈកំហែងបង្ខំដ៏ខ្លាំងក្លានៃបុរស នាងក៏ឱនគំនាប់ទទួលយកកែវសុរា អំពីព្រះហស្តរានី ។ ក្នុងខណៈដែលនាងកំពុងយាងចូលទៅកាន់បន្ទប់នោះ នាងនឹកតែក្នុងព្រះទ័យថា «វេលានេះ យើងចូលទៅក្នុងទីចម្រូងចម្រាស់ដូចជាចូលទៅក្នុងរង្វង់ស្នែងសត្វ យើងមិនដឹងបើនឹងប្រតិបត្តិដូចម្ដេចឲ្យរួចខ្លួនទេ, បើយើងទទឹងអាជ្ញារានីសោត ទោសទណ្ឌកម្មមុខជានឹងធ្លាក់លើខ្លួនយើងមិនខាន, ឥឡូវបើនឹងប្រថុយចូលទៅរកកិច្ចកៈ សេចក្ដីសៅហ្មងមុខជានឹងមានដល់ខ្លួនយើងជាប្រាកដ សឹងនឹងគេចវេះទៅផ្លូវណា ក៏មិនរួចខ្លួនដែរ, ប្រសិនបើយើងប្រតិបត្តិតាមបញ្ជារានីហើយ អ្នកណានឹងធានាបានថា ការចូលទៅក្នុងបន្ទប់ស្ងាត់តែពីរនិងពីរ ហើយគ្មានគ្រឿងការពារខ្លួនផង វានឹងមិនឲ្យទោសដល់ខ្លួនយើងដូចម្ដេចបាន, អ្នកណានឹងធានាបានថា កិច្ចកៈនឹងមិនធ្វើអ្វីដល់យើងនោះ ? រឿងនេះសូម្បីតែស្ត្រីអ្នកព្រៃផ្សៃដែលស្លូចស្តើងចរិយាសម្បត្តិ គេក៏គង់តែខ្លាចច្រើន ស្មើនឹងខ្លាចខ្លាដែរ, ប៉ុន្តែទោះបីដូចម្ដេចក្តី យើងនឹងខំប្រឹងព្យាយាមរក្សាកិត្តិយើង ទុកឲ្យពេញកម្លាំងតាមការដែលអាចនឹងរក្សាបាន ទោះបីនឹងខូចបង់ជីវិត ក៏តាមការចុះ, សូមព្រះជាម្ចាស់លើស្ថានសួគ៌ ជួយអភិបាលរក្សាខ្ញុំម្ចាស់ក្នុងគ្រានេះ

ផង» ។ ដោយគំនិតយ៉ាងនេះ ជារណបគាំពារផង នាងក៏ប្រថុយឈានជើងចូលទៅក្នុងបន្ទប់កិច្ចកៈ ។ ឯហេតុការណ៍ដែលកើតឡើងនោះ ក៏វាមិនខុសអ្វីពីគំនិតដែលនាងគិតស្មានទុកនោះឡើយ ។ កិច្ចកៈ កាលបើបានឃើញនាងចូលទៅតែម្នាក់ឯង ក៏នឹកញញឹមប្រិមប្រិយក្នុងចិត្ត ខំក្រោកឡើងស្ទុះមកប្រុងនឹងស្រវាឱបនាង ។ នាងគ្មានអាវុធសម្រាប់ការពារខ្លួនក៏ពិតមែនហើយ ប៉ុន្តែនាងប្រុងទុកតស៊ូដោយកម្លាំងកាយ នាងទះតប់ ខ្វារ ខ្វាំ បម្រាសទាល់តែរបូតផុតអំពីដៃកិច្ចកៈ ដែលកំពុងស្រវឹងសុរា ស្ទុះដើរចេញពីបន្ទប់មកក្រៅ ។

ព្រះបាទក្រុងវិរាជ នៅពេលនោះកំពង់គង់ក្នុងព្រះទីនាំងវិនិច្ឆ័យ ។ ខណៈនោះ មានស្ត្រីម្នាក់ស្រែករត់ចូលទៅមុខព្រះទីនាំងហើយចូលទៅដល់បល្ល័ង្កដែលទ្រង់គង់ ដោយអាការៈក្លាហាននឹងស្រែកយ៉ាងខ្លាំងថា «អយុត្តិធម៌ ! អយុត្តិធម៌ ដ៏លាមកកើតឡើងក្នុងម្លប់សាលាយុត្តិធម៌ហើយ ព្រះរាជាអើយ ! កាលស្ត្រីភាពអ្នកមានកម្លាំងតិច ឥតទីពំនឹងមកត្រូវគេញាំញីសម្នានស័ក្តិលេងតាមអំពើចិត្តខាងក្នុងកំពែងបួនជាន់ នៃព្រះបរមរាជវាំងរបស់ព្រះអង្គដូច្នេះ សេចក្តីវិនាសក៏សស្បៀវចូលជិតព្រះអង្គណាស់ហើយ» គ្រានោះ មានអ្នកបម្រើម្នាក់ខំបណ្តេញនាងចេញអំពីទីនោះ ហៅនាងថា «មេចំក្លួត, មេកំព្រើល, និយាយព្រើល ៗ ផ្តេសផ្តាស»។ ពេលនោះ កិច្ចកៈដេញតាមស្លុងចូលមកក្នុងរោងគាល់ ចាប់សក់នាងទាញដឹក



យកទៅអំពីទីប្រជុំនោះ ។ អ្នកដែលនៅអង្គុយគាល់ទាំងនោះ មិនទាន់បានដឹងថា កើតហេតុរឿងអ្វីឡើយ ។ កាលកិច្ចកៈអូសទាញនាងចូលទៅវាំងវិញ សៃរិន្ទ្រីបានស្រែកចប់តាមផ្លូវ សុំឲ្យប្រុសម្នាក់ដែលឈរនៅជិតទីនោះជួយនាងផង ហើយនាងមើលទៅដូចជាស្គាល់ប្រុសនោះដែរ ។ ប៉ុន្តែឯប្រុសនោះយល់ឃើញថា មិនគួរនឹងធ្វើឲ្យកក្រើករឹករវចលាចលកណ្តាលផ្លូវថ្នល់ទេ គ្រាន់តែឱនខ្សឹបប្រាប់នាងថា ឲ្យនាងធ្វើឫកមារយាទឱនលំទោន ព្រមតាមគេទៅសិនចុះ ចាំដល់វេលារាត្រីនឹងមានពួកយើងមកជួយ យើងមកនៅជិត ៗ នាងដើម្បីនឹងជួយឲ្យរួចអំពីសេចក្តីអប្បយសនេះ ។

សៃរិន្ទ្រីក៏ប្រតិបត្តិតាមពាក្យគេខ្សឹបប្រាប់ ។ នាងនៅស្ងៀមលែងសម្តែងអាការៈរឹងទទឹងអ្វីសោះ ដើរតាមកិច្ចកៈចូលទៅក្នុងបន្ទប់ដោយស្រួល ។ កាលអ្នកទាំងពីរចូលផុតទៅហើយ កិច្ចកៈក៏ចាក់គន្លឹះទ្វារគ្រឹប ហើយនិយាយប្រលោមលួងលោមនាងថា «កុំណា ! កុំកាត់មេត្រីក្តីស្នេហារបស់បងឡើយ ! វង់ភក្ត្រដ៏ត្រឡប់ដូចវង់ខែនេះ មកបណ្តាលឲ្យបងវង្វេងស្មារតីអស់ ក្តីស្នេហាដ៏ធ្ងន់មហិមាស្មើមហាបពិត បានចូលមកគ្របសង្កត់ហឫទ័យរបស់បង, វេលានេះខ្លួនបងធ្លាក់ទៅជាទាសៈនៃសេចក្តីស្រឡាញ់ហើយ គ្មានអ្វីនឹងមកបន្ធូរបន្ថយបានទេ ក្រៅអំពីនាងព្រមព្រៀងទទួលប្រតិព័ទ្ធផងប៉ុណ្ណោះ កុំខឹងសម្បាអ្វីឡើយណាស្រស់ស្រី ! បងសូមផ្ញើមេត្រីក្តី

ស្នេហាលើសបប្អូនផង កុំឲ្យបងស្លាប់បង់អសារឥតការ» ។ លំដាប់នោះ កិច្ចកៈខិតចូលជិតនាង លាព្រះពាហាជាអាការបបួលឲ្យនាងឱបហើយលួងលោមតទៅទៀតថា «សុំឲ្យបងឱបរឹតផ្ដិតទ្រូងបន្តិចស្រស់ស្រី ! ដើម្បីបន្ទោបង់នូវសេចក្ដីក្រហល់ក្រហាយ ដែលរុំរឹតចិត្តបង, តពីនេះទៅបងក៏ជាសម្បត្តិរបស់នាង, នាងក៏ជាសម្បត្តិរបស់បងជានិច្ចនិរន្តរទៅ ណ៎ាពៅព្រលឹង !»។

សៃរិន្ទ្រីញញឹមដោយឧបាយកល ហើយក៏នៅតែស្ងៀម ពុំមានឆ្លើយឆ្លងថាអ្វីឡើយ ។

កិច្ចកៈបានចិត្ត ក៏និយាយប្រលោមលួងលោម តទៅទៀតថា «សេចក្ដីអៀនខ្មាសឃើញកើតមានប្រាកដ នៅត្រង់ទឹកមុខយុវតីសៃរិន្ទ្រី វាមកអុជកងអគ្គីក្នុងទ្រូងបងឲ្យក្ដៅរោលរាល, កុំគេចមុខដ៏បំព្រងដូចដួងខែអំពីការសម្លឹងរបស់រៀមឡើយ, កុំស្ងាត់កុំស្ងៀមសំដីដ៏ពីរោះស្រណោះសោត ចូរនាងបញ្ចេញប្ដេជ្ញាមកតែមួយមាត់ អំពីវរឱស្ឋប៉ប្រិមដូចទទឹមព្រាយ ក៏អាចនឹងជួយរំសាយទុក្ខ ហើយជ្រោមជ្រែងជីវិតបងឲ្យគង់ទ្រង់តទៅទៀតបាន» ។

ក្នុងទីបំផុត សៃរិន្ទ្រីតបស្នងវាទីថា «ម្ដេចក៏ទ្រង់ប្រញាប់ប្រញាល់ម្ល៉េះ សូមបង្អង់ចាំឲ្យដល់យប់សន្ធ្យាសិន ខ្ញុំម្ចាស់នឹងគេចទៅណា !» ។

«នាងដឹងបានដោយក្រណាស់ សម្រាប់ចិត្តអ្នកគូសម្លាញ់



ដែលកំពុងតែជ្រួលច្របល់គ្រប់ខណៈដង្ហើមចេញចូល នឹងបង្អង់ចាំពេលនេះ ពេលនោះដូចម្ដេចកើត» កិច្ចកៈឆ្លាសឆ្លើយដោយសម្លេងញ័ររន្ធាន់ ។

សៃរិន្ទ្រី មានសេចក្ដីអៀនខ្មាសក្នុងពេលនេះហួសប្រមាណ ប៉ុន្តែនាងក្លែងធ្វើឧបាយកលជាមុខញញឹមញញែម ហើយទទួលប្ដេជ្ញាថា «នឹងចូលមករកទ្រង់ក្នុងវេលាយប់នេះជាមិនខាន សូមទានឲ្យតែបន្ធូរបន្ថយសិនចុះ» ។

កិច្ចកៈនិយាយម្ដងទៀតជាទីបំផុតថា «បងពេញចិត្តណាស់ និងអរគុណប្អូនយ៉ាងក្រៃលែង, មធុរកថារបស់ប្អូនប៉ុណ្ណេះ អាចជួយរក្សាដួងចិត្តជីវិតរបស់បងឲ្យគង់នៅ បានឃើញពន្លឺព្រះអាទិត្យតទៅទៀត, គ្រានេះបងត្រឡប់ដឹងខ្លួនដូចអំពីដើមវិញហើយ ជីវិតរបស់បងនេះ ប្រសិនបើជាមានប្រយោជន៍ដល់នាងសូម្បីតែបន្តិចបន្តួចក្ដី ក៏បងស៊ូលះបង់ឲ្យប្អូនដែរ» ។

សម្រាប់ចិត្តគូសម្លាញ់ដែលទើបស្រឡាញ់គ្នាថ្មី ៗ ក្ដៅ ៗ សំគាល់ថា ពេលវេលាដែលកន្លងទៅយឺតយូរណាស់ ត្រូវត្រង់តម្រាភាសិតថា «រាល់ ១ ម៉ោងដែលកន្លងម្សិត ១ ឃើញដូចជាយឺតយូរស្មើនឹងអាយុកាល, បីដូចជាកង់រថព្រះអាទិត្យជាប់ផុកផង់, ទោះបីដូច្នោះក្ដី រាត្រីកាលនឹករន្ធឹងរន្ធាន់ក្នុងចិត្ត ក៏បានមកដល់ក្នុងទីបំផុត, វេលាសន្ធ្យាចរមកដល់ មានស្រមោលងងឹតព្រឹល ១ ឆ្ពោងទៅខាង

ខ្មៅ បានជួយឧបត្ថម្ភចិត្តកិច្ចកៈដែលកំពុងតែដើរញាប់តឹក ៗ ឲ្យរីករាយឡើងបានបន្តិច ដោយមានសេចក្តីសង្ឃឹមកើតឡើង ប៉ុន្តែមកដល់ពេលនេះហើយ ឃើញនាឡិការហាក់ដូចជាដើរវឹតតែយឺតយូរជាងសព្វដងណាស់ទៅទៀត, កិច្ចកៈផ្ទំលើព្រះទែនប្រុងស្មារតីចាំស្តាប់សូរស័ព្ទជើងនាងឆោមឆើតដើរចូលមករកខ្លួន ។ ក្នុងទីបំផុតទ្វារបន្ទប់នោះក៏សន្សឹម ៗ បើកបន្តិចម្តង ៗ រូបស្រស់បំព្រងតែងខ្លួនទងវងជជាយបានចូលទៅដល់ក្នុងបន្ទប់នោះ ។ កិច្ចកៈក្រឡេកឃើញញញឹញញញ់ ក្រោកឡើងអង្គុយ ហើយអញ្ជើញឲ្យនាងអង្គុយក្នុងរង្វង់ដៃ ។ នាងសន្សឹម ៗ ដើរចូលទៅកាន់ទីព្រះទែន ដោះគ្រឿងតែងកាយជាន់ក្រៅចេញភ្លាម ។ យីអើ ! មិនមែនស្រីទេតើ, កិច្ចកៈឃើញច្បាស់ទៅជាអ្នកចម្បាំងម្នាក់ រូបរាងធំសម្បើមមកឈរចំពោះមុខគេ ហើយស្រែកគំរាមថា «អាខ្មោចឥតខ្មាស ! អាឯងមិនដឹងទេឬធម្មតាជាស្ត្រីល្អបរិសុទ្ធមិនលក់កិត្តិយសរបស់ខ្លួន ព្រោះតែឃើញលុយកាក់ទេ ? ឥឡូវនេះ អាឯងចូរប្រុងប្រៀបខ្លួនពីរឿងចិត្តខ្មៅរបស់អាឯង ដើម្បីនឹងចុះទៅកាន់នរិយភូមិជាឆាប់ចុះ» និយាយតែប៉ុណ្ណោះគេក៏ចាប់កិច្ចកៈទាញកន្ត្រាក់ចេញពីព្រះទែន ប្រហារជីវិតដោយក្តាប់ដៃដ៏មានឫទ្ធិឲ្យស្លាប់បង់ទៅ ។ ភីម អ្នកក្លែងខ្លួនជាស្ត្រីក៏ប្រវាឡើងកំពែងវាំងកិច្ចកៈចុះទៅដេកធ្វើព្រងើយ គ្មានអ្នកណាម្នាក់ក្នុងវាំងនោះដឹងថាមានហេតុភេទអ្វីកើតឡើងក្នុងរាត្រីនោះសោះ ។



លុះដល់ព្រឹកឡើងទាល់តែថ្ងៃរះខ្ពស់ បន្ទប់ទីបន្ទំរបស់កិច្ចកៈនៅតែបិទទ្វារជិតឈឹង ។ អ្នកទាំងពួងនឹកសង្ស័យណាស់ មានម្នាក់ទទួលសវនីយ៍ទៅពិនិត្យមើលដើម្បីឲ្យដឹងថាមានហេតុភេទដូចម្តេច ? អ្នកបម្រើនោះ កាលបើកទ្វារចូលទៅហើយ ស្រាប់តែទចង់ក់ធ្វើភ្នែកគ្រលួង ព្រោះឃើញសពកិច្ចកៈដេកស្តូក លោហិតច្រាលរន្ទាលពាសពេញល្វែង និងប្រឡាក់នៅជាប់ខ្លួនសព ។ កាលបើសេចក្តីនោះជ្រួតជ្រាបទៅដល់ព្រះញាតិវង្ស, ព្រះញាតិវង្សក៏ភ្ញាក់ផ្អើលឆោឡោតែរាល់អង្គ ។ ឯរានីជាព្រះជេដ្ឋភគិនីក៏ទៅជាខ្យល់ចាប់សន្លប់បាត់ព្រះស្មារតី ។ ដោយអំណាចទោសោឃោរឃៅ អ្នកទាំងនោះក៏រករឿងចោទថា «នាងទាសីជាអ្នកសម្លាប់» ប៉ុន្តែឥតស្មរបន្ទាល់ល្មមយកជាការពិតបាន ព្រោះមានគំនិតយល់ឃើញថា «ស្ត្រីមុខជាមិនអាចធ្វើឃាតកម្មប្រុស ដែលមានរូបរាងធំមាំមួនដូចកិច្ចកៈនេះបានឡើយ» សូម្បីយល់យ៉ាងនេះហើយក្តី មនុស្សទាំងពួងក៏មិនអស់សង្ស័យ នៅតែចូលចិត្តថា «រឿងឃាតកម្មគ្រានេះជាករណីយហេតុដ៏ស្ងាត់កំបាំង» ។ ប៉ុន្តែរានីទ្រង់នឹកសង្ស័យត្រង់ការដែលថា «សៃរិន្ធ្រីជាអ្នកដើមហេតុ» ដោយហេតុនេះ ព្រះនាងមិនបានបិទបាំងរឿងសង្កានេះទុកឡើយ តែងត្រាស់ប៉ោច ៗ ជាញយ ៗ ថា «តែឃើញមុខនាងទាសីកាលណា ឲ្យនឹកជិននឹកជិតក្នុងចិត្ត» ព្រោះតែឃើញហើយ បណ្តាលឲ្យហាឫទ័យព្រះនាងនឹកដល់មរណកម្មរបស់

ព្រះអនុជ ។ ក្នុងទីបំផុតព្រះរាជា ក៏ត្រូវខ្យល់កំបុតត្បូងមកក្ដួចត្រឡប់ត្រឡិននាំឲ្យជឿពាក្យព្រះមហេសី, ទ្រង់ត្រាស់បញ្ជាឲ្យចងជើងចងដៃសៃរិន្ទ្រី ហើយឲ្យនាំយកទៅដុតទាំងរស់ជាមួយនឹងសពកិច្ចកៈលើជើងថ្កររួមគ្នា ។

នាងទាសីសៃរិន្ទ្រីត្រូវគេចងទុកផ្ងាញ់ផ្ងាលជាច្រើនម៉ោង ដើម្បីនឹងឲ្យនាងទទួលសារភាពតាមការពិត ។ ប៉ុន្តែនាងខំអត់ធន់ចំពោះទារុណកម្មនោះ ដោយសេចក្ដីមានះក្លាហាន ព្រោះឈ្វេងយល់ច្បាស់ថា ពួកបាណ្ឌពក្សត្រិយ៍នឹងមកជួយនាងឲ្យរួចអំពីភ័យក្នុងវេលាមានឱកាស ។ ការដែលនាងត្រូវគេចងដៃចងជើងរឹតរួតរឹងក្រញង់ ដូចជាគេចងជ្រូកនោះ មិនធ្វើឲ្យរានីមានសេចក្ដីសង្វេគវេទនាសោះ ព្រោះនៅវេលានោះ ព្រះនាងកំពុងតែពេញពោរទៅដោយសេចក្ដីទុក្ខសោក នឹករឭកអាឡោះអាល័យព្រះអនុជដែលក្ស័យព្រះជន្មទៅ ទ្រង់ដឹតព្រះទ័យនឹងនាងទាសីយ៉ាងខ្លាំង ។

គ្រានោះ គេបណ្ដើរនាងទៅឯសុខសាន្តប្រទេសមានទាហានប្រមាណ ៥០ នាក់ ឃុំខ្លួននាងទៅ ដើម្បីការពារកុំឲ្យនាងរត់រួច និងចាំការពារកុំឲ្យពួកញាតិរបស់នាងចូលមកដណ្ដើមយកខ្លួននាងទៅបាន ។ ទីមេរុនោះ គេបានចាត់ចែងតម្កល់ជើងថ្ករត្រៀមទុកថ្វាយព្រះភ្លើងសពកិច្ចកៈ ។ ចំណែកនាងក៏ត្រូវគេបង្គាប់ឲ្យឡើងទៅដុតខ្លួនសម្លាប់លើជើងថ្ករនោះជាមួយនឹងសពកិច្ចកៈ ដែលគេចោទប្រកាន់



ថានាងជាអ្នកសម្លាប់ ។ ប៉ុន្តែមុននឹងឡើងទៅលើជើងថ្ករ គេបានអនុញ្ញាតឲ្យនាងប្រកាសសេចក្ដីណាមួយមុននឹងលាស្លាប់ ប្រសិនបើនាងមានបំណងនឹងថ្លែងបច្ឆិមវាចា ។ លំដាប់នោះ នាងក្រោកឈរឡើងដោយអង់អាច ហើយបរិយាយដោយសម្លេងយ៉ាងច្បាស់លាស់ក្បោះក្បាយ ឥតញញើតរស្លុតរន្ធត់ថា «ម្នាលសុភាពបុរសទាំងឡាយប្រសិនបើអ្នកមកនឹកគិតមើលមួយរំពេចថា «បើមាតា ឬបងស្រី, ប្អូនស្រី, បុត្រីរបស់អ្នកបានទទួលនូវសេចក្ដីអប្បយសអាម៉ាស់មុខ ព្រោះតែប្រុសដែលស្លាប់ទៅនេះ, ទាំងនាងនោះឯងក៏មិនពេញចិត្តយកសម្មានចិត្តស័ក្ដិយសខ្លួនមកប្ដូរនឹងប្រុសនេះ ដូចយ៉ាងខ្លួនខ្ញុំនេះ តើអ្នកនឹងចងដៃ ចងជើងយកនាងទៅដុតទាំងរស់ ព្រោះហេតុតែនាងខំប្រឹងការពារសេចក្ដីបរិសុទ្ធរបស់នាងនោះដែរឬ ? ខ្ញុំជឿថា អ្នកទាំងពួងមុខជាប្រកែកព្រមគ្នាថា «នឹងមិនធ្វើទោសទណ្ឌកម្មអ្វីដល់នាងនោះឡើយ, បើដូច្នោះសោត ហេតុម្ដេចស្ត្រីកំសត់ទុគ៌ត គ្មានផ្ទះសម្បែងនៅសំណាក់អាស្រ័យ គ្មានញាតិវង្ស គ្មានអាហារបរិភោគចិញ្ចឹមជីវិត រស់នៅទាំងត្រដរត្រដាបត្រដួស ដោយសារតែគេឲ្យទានហើយមកត្រូវទោសដូច្នេះ មិនខុសពីអ្នកទាំងពួងទៅហើយឬ ?» ។

ក្នុងមួយវិនាទី ឬពីរបីវិនាទីទៀត ខ្ញុំផុតជីវិតសូន្យបង់ គ្មានខ្លួនប្រាណទេ ! ប៉ុន្តែសុទ្ធចិត្តរបស់ខ្ញុំ នឹងត្រាច់រង្គាត់ទៅក្នុងលោក, ចិត្តរបស់នាង ព្រហ្មចារិនីមិនចេះស្លាប់សោះឡើយ» ។

លុះនាងនិយាយចប់ផុតពីមាត់ភ្លាម លេចបុរសម្នាក់ខ្មៅ មាឧធំមាំសម្បើមរត់សំដៅទៅមាត់ទន្លេត្រង់កន្លែងដែលគេរៀបចំថ្វាយព្រះភ្លើងសពកិច្ចកៈ ។ បុរសនោះរត់ចូលមករលះរលាំងស្រែកបណ្តើរថា «ខ្លួនខ្ញុំកាន់ព្រះរាជសាសន៍ មកធ្វើការយ៉ាងប្រញាប់ណាស់» ។ គេរត់ចូលយ៉ាងល្បឿនព្រីល ល្បឿនទាល់តែអ្នកនៅចាំប្រយ័ត្នការ នឹងហាមឃាត់ ឬសួរយកដំណឹងពុំទាន់ ឥតដឹងជាអ្នកនោះចូលមកដោយការល្អ ឬអាក្រក់សោះ ។ គេដល់ទីប្រជុំជន រត់កាត់ហ្វូងពួកអ្នកយាមល្បាតរក្សាការពារ ដែលឈរត្រៀបត្រាជុំវិញជើងថ្ករ ។ ក្រប៊ីដែលគេកាន់នៅដៃ គេវាត់ឆ្វេង វាត់ស្តាំ ត្រូវមនុស្សដាច់កធ្លាក់ក្បាលពីស្មាដួលរណែល ហើយស្រែកប្រកាសដោយសម្លេងយ៉ាងឮខ្លាំងថា «កិច្ចរបស់យើងដែលស្ទុះរត់ចូលមកទាំងប្រញាប់ប្រញាល់យ៉ាងនេះ ដោយប៉ុនប៉ងមកជួយសង្គ្រោះជីវិតស្ត្រីដែលជាប់ចំណងនេះ, កិច្ចតទៅទៀត យើងនឹងសម្តែងឲ្យអ្នករាល់គ្នាឃើញថា «ដៃកត្ចូចវែងដ៏មុតនេះ (គេយកដៃចង្អុលក្រប៊ី) នឹងប្រហារក្បាលអ្នករាល់គ្នា ឲ្យកំបុតត្រឹមបាន» ។

គេស្រែកឃោសនាដូច្នោះហើយ ក៏ស្ទុះប្រវាឡើងទៅលើជើងថ្ករ ចាប់ស្រាយចំណងឲ្យរបូតចេញពីខ្លួននាងសៃរិន្ធ្រី ហើយនាំចុះមកដី ។ នៅគ្រាចុះមកដល់ដីរាបនោះ មានការតស៊ូកាប់សម្លាប់គ្នានឹងពួកយាមល្បាតមួយភ្លើងធំ គេវាត់ឆ្វេង ក្របែលស្តាំដោយក្រប៊ីសម្រាប់ដៃ ខ្លះដាច់ក, ខ្លះដាច់ដៃ, ខ្លះដាច់ជើង ស្លាប់ភ្លាមទៅប្រហែល ២០ នាក់, ឈាមបាចសាចពាសពេញមាត់ទន្លេ ។ ទីឈាបនកិច្ចក៏បានប្រែក្លាយទៅជាទីយុទ្ធភូមិ ពោរពេញទៅដោយលោហិតមនុស្ស ។ អ្នកដែលរស់រួចជីវិតនៅ ក៏មិនសូវជាច្រើនប៉ុន្មានដែរ ។ ឯអ្នកបានរួចខ្លួនពីមុខក្រប៊ី សុទ្ធតែជាមនុស្សគេចខ្លួនរត់បាត់ទៅជាមុន ។ លុះស្រេចការកាច់កិនសត្រូវដោយកម្លាំងដ៏ខ្លាំងក្លា មុខគួរឲ្យព្រឺព្រួចរោមប៉ុណ្ណោះហើយ បុរសខ្មៅមាឧធំមាំនោះក៏ត្រកងនាងដាក់លើស្មា លីរហោចចេញបាត់ទៅក្នុងរយៈផ្លូវដ៏ឆ្ងាយដាច់កន្ទុយភ្នែក ។